# ប្រតិទិនពិធីបុណ្យខ្លះៗនៅតំបន់អង្គរ



រៀបចំដោយៈ ទិន  ទីណា, អ៊ូ គង្គា, តូច  សុកៈ, ផាន់  សុភានី និង ជា សំបូរ

ដឹកនាំដោយ

ឯកឧត្តម ឡុង  កុសល

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ

ឆ្នាំ២០២៤

# មាតិការ

សេចក្តីផ្តើម……………………………………………………………………………………………
ពិធីបុណ្យខ្លះៗនៅតំបន់អង្គរ……………………………………………………………………………
ប្រតិទិនបុណ្យខ្លះៗនៅតំបន់អង្គរ………………………………………………………………………
១. ពិធីបុណ្យក្នុងបរិបទកសិកម្ម……………………………………………………………………
១.១. ឡើងមាឃ…………………………………………………………………………………………
១.២. បួងក្រឡាន………………………………………………………………………………………
១.៣. ធ្វើងបែត្រ…………………………………………………………………………………………
១.៤. សុំទឹកភ្លៀង………………………………………………………………………………………
១.៥. សំពះព្រះខែ ឬអកព្រះខែ…………………………………………………………………………
២. បុណ្យភូមិ…………………………………………………………………………………………
២.១. ឆាន់ភូមិ/ឆាន់សាន ………………………………………………………………………………

២.២. ដាក់ដំណាក់ទឹកស្រក និងដាក់ដំណាក់ទឹកឡើង……………………………………………………………………………

២.៣. សម្ភោធភូមិ……………………………………………………………………………………………………………

២.៤. បុណ្យបញ្ចូន……………………………………………………………………………………………………………

៣. ធ្វូងវ័យ ……………………………………………………………………………………………………………………

៣.១. កាត់សក់ បង្កក់ធ្មេប ………………………………………………………………………………………………

៣.២. កោរជុក……………………………………………………………………………………………………………………

៣.៣. បូជាសព……………………………………………………………………………………………………………………

៣.៤. ចម្រើនអាយុ……………………………………………………………………………………………………………

៣.៥. បួស…………………………………………………………………………………………………………………………

៤. ពិធីក្នុងគ្រួសារ ………………………………………………………………………………………………………………

៤.១. កាត់គ្រោះ ………………………………………………………………………………………………………………

៤.២. លៀងមេមត់ ……………………………………………………………………………………………………………

៥. ពិធីបុណ្យក្នុងពុទ្ធសាសនា……………………………………………………………………………………….
៥.១. ចូលបរិវាសកម្ម……………………………………………………………………………………………….
៥.២. មាឃបូជា ………………………………………………………………………………………………………….
៥.៣. ទេសន៍មហាជាតក ……………………………………………………………………………………………….
៥.៤. វិសាខបូជា ………………………………………………………………………………………………………….
៥.៥. ចូលវស្សា ………………………………………………………………………………………………………….
៥.៦. ចេញវស្សា ………………………………………………………………………………………………………….

# សេចក្ដីផ្ដើម

អង្គរជាអារ្យធម៌មួយបានចម្រើនលូតលាស់បន្តិចម្ដងៗរហូតបានក្លាយជាអារ្យធម៌រុងរឿង ខ្ពង់ខ្ពស់ក្នុងអំឡុងស.វ.ទី៩ដល់ស.វ.ទី១ ៤។ ភាពរុងរឿងក្នុងរយៈពេលដ៏វែងនេះ បានបន្សល់ទុកនូវមតករូបី និងអរូបីច្រើនរាប់មិនអស់នៅកម្ពុជានិយាយជារួម និងនិយាយដោយឡែកនៅតំបន់អង្គរ។ ក្នុងនោះមរតករូបីមាន៖ បុរាណដ្ឋាន ប្រាសាទ បដិមា សិលាចារិក ព្រះរាជវាំង វត្តអារាម ស្ពាន ថ្នល់ បណ្ដាញផ្លូវទឹក បារាយណ៍ ភូមិស្រុក ស្រែ ចម្ការ។ល។ ដោយឡែកមរតកអរូបីមានដូចជា៖ ចំណេះដឹង ជំនាញ កិច្ចពិធី ទំនៀមទម្លាប់ប្រពៃណី ស្នាដៃសិល្បៈ ដែលបានផ្ទេរពីមនុស្សមួយជំនាន់ទៅមនុស្សមួយជំនាន់ទៀតឥតដាច់។ មរតកដ៏ត្រចះត្រចង់នៅតំបន់អង្គរដែលសល់ដល់សព្វថ្ងៃនេះ ក៏ជាលទ្ធផលផ្សំវេញបញ្ចូលផ្គុំចាក់ស្រេះចូលគ្នារវាងជំនឿជីវចលដែលជាជំនឿដើមរបស់អ្នកស្រុក និងព្រហ្មញ្ញសាសនា ពុទ្ធសាសនាមហាយាន្ត និងពុទ្ធសាសនាថេរវាទ ព្រមទាំងអ្វីៗជាច្រើនទៀត បានក្លាយមកជាខឿនអារ្យធម៌ខ្មែរដ៏រឹងមាំ និងឧត្តុង្គឧត្ដមយ៉ាងក្រៃលែង។ តម្លៃអារ្យធម៌អង្គរដ៏វិសេសវិសាលទាំងអស់នោះហើយដែលខ្មែរទាំងអស់គ្នាចាត់ទុកថា «អង្គរជាដួងព្រលឹងជាតិខ្មែរ»។

សហគមន៍មនុស្សគ្រប់សម័យកាលរហូតដល់សព្វថ្ងៃនេះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយប្រាសាទ បុរាណដ្ឋាន និងបរិស្ថាននៃតំបន់អង្គរ។ ចំពោះអ្នកស្រុកអង្គរសព្វថ្ងៃនេះ ប្រាសាទជាទីសក្ការៈសម្រាប់អមនុស្សរស់នៅ ដែលគេអាចពឹងពាក់អាស្រ័យអមនុស្សទាំងនោះសម្រាប់កិច្ចការសង្គម កសិកម្ម និងការព្យាបាល ស្ដែងចេញតាមរយៈការរៀបចំកិច្ចពិធីផ្សេងៗតាមទំនៀមទម្លាប់ប្រពៃណី សាសនា។ ឯបរិស្ថាននៅតំបន់អង្គរក៏បានផ្ដល់អំណោយផលដល់ការប្រកបរបរចិញ្ចឹមជិវិតប្រចាំថ្ងៃតាមទម្លាប់អ្នកស្រុកមានដូចជា៖ ដីស្រែ ចម្ការ ម្ហូបអាហារ ឱសថបុរាណ របស់របរប្រើប្រាស់បែបហត្ថកម្មប្រពៃណីដែលជាលក្ខណៈពិសេសក្នុងតំបន់។

សព្វថ្ងៃនៅតំបន់អង្គរ មានកិច្ចពិធីប្រពៃណីតាមរដូវកាលជាច្រើនបានគ្របដណ្ដប់លើជីវិតរស់នៅ និងបន្តគោរពប្រតិបត្តិដោយអ្នកស្រុកអង្គរ ព្រមទាំងមានទំនាក់ទំនងជាមួយសហគមន៍រស់នៅក្នុងតំបន់អង្គរទាំងមូលដូចជា៖ ពិធីទាក់ទងនឹងការធ្វើកសិកម្ម ពិធីឆ្លង

*វ័យ ដែលជាពិធីមួយទាក់ទងនឹងកំណើត មង្គលការ និងបុណ្យខ្មោចៗ ពិធីប្រចាំគ្រួសារ ពិធីទាក់ទងភូមិដ្ឋាន និងពិធីសាសនាៗលៗ សព្វថ្ងៃនេះ កិច្ចប្រតិបត្តិជំនឿ សាសនា និងពិធីបុណ្យមួយចំនួននៅតំបន់អង្គរបានថមថយចុះខ្សោយ ដោយសារការប្រែប្រួលនៃសហគមន៍ដែលស្ថិតនៅក្នុងបរិបទសង្គមទំនើប ព្រមទាំងឥទ្ធិពលផ្សេងៗនៃសាកលភាវូបនីយកម្មៗ យើងតែងសង្កេតឃើញថា សាសនាតែងមានវត្តមាននៅស្ទើរគ្រប់បុណ្យទាំងអស់ ទោះជាបុណ្យទាក់ទងនឹងកសិកម្ម បុណ្យភូមិ ពិធីឆ្លងវ័យ និងពិធីក្នុងគ្រួសារដែលជាបុណ្យមិនទាក់ទាក់និងព្រះពុទ្ធសាសនាសោះក៏គេនិមន្តព្រះសង្ឃមកធ្វើកិច្ចដែរ ពោលគឺពុំមានបុណ្យណាក្រៅសាសនាសុទ្ធ ឬបុណ្យណាមានតែសាសនាសុទ្ធនោះទេ ពោលគឺតែងតែលាយគ្នាជានិច្ច ព្រោះជីវិតសង្គមនៅជនបទ គឺមិនអាចដាច់គ្នាទេ ម្យ៉ាងទៀតព្រះសង្ឃទាំងអស់សុទ្ធតែជាកូនអ្នកស្រុកៗ*

## ពិធីបុណ្យខ្លះៗនៅតំបន់អង្គរ

| បុណ្យទាក់ទងនឹងកសិកម្ម | បុណ្យភូមិ | ពិធីឆ្លងវ័យ | ពិធីក្នុងគ្រួសារ | ពិធីបុណ្យក្នុងពុទ្ធសាសនា |
|---|---|---|---|---|
| • *ឡើងមាឃ* | • *ឆាន់ភូមិ/ឆាន់សាន* | • *កាត់សក់បង្កក់ធ្មប* | • *កាត់គ្រោះ* | • *ចូលបរិវាសកម្ម* |

| | | | | |
|---|---|---|---|---|
| • បុងក្រឡាន | • ដាក់ដំណាក់ទឹកស្រែក និងដាក់ដំណាក់ទឹកឡើង | • កោរជុក | • លៀងមេមត់ | • មាឃបូជា |
| • ឆ្លងចៃត្រ | • សម្ភោធភូមិ | • បូជាសព | | • ទេសន៍នាមហាជាតក |
| • សុំទឹកភ្លៀង | • បុណ្យបញ្ចូន | • ចម្រើនអាយុ | | • វិសាខបូជា |
| • បុណ្យព្រះខែ ឬអកព្រះខែ | | • បួស | | • ចូលវស្សា |
| | | | | • ចេញវស្សា |

នៅទីនេះ យើងលើកយកតែពិធីបុណ្យខ្លះៗដែលនៅបន្តប្រតិបត្តិនៅតំបន់អង្គរមកបង្ហាញ ចំណែកពិធីបុណ្យក្នុងសាសនាក៏នឹងលើកមកបង្ហាញខ្លះៗតែប៉ុណ្ណោះ ដ្បិតពិធីនេះមានប្រារព្ធស្ទើរតែគ្រប់កន្លែងទាំងអស់នៅកម្ពុជា។ ចំណែកប្រតិទិនបុណ្យតាមប្រពៃណីដែលបានធ្វើកន្លងមក មានតាមលំដាប់លំដោយដូចខាងក្រោមនេះ គឺអ្នកស្រុកគិតតាមខែច័ន្ទគតិ ពោលចាប់ផ្ដើមពីខែមគ្គសិរ (ខែធ្នូ)។

# ប្រតិទិនបុណ្យខ្លះៗនៅតំបន់អង្គរ

| កិច្ចពិធី | មិគ្គសិរ (ធ្នូ) | បុស្ស (មករា) | មាឃ (កុម្ភៈ) | ផល្គុន (មីនា) | ចេត្រ (មេសា) | ពិសាខ (ឧសភា) | ជេស្ឋ (មិថុនា) | អាសាឍ (កក្កដា) | ស្រាពណ៍ (សីហា) | ភទ្របទ (កញ្ញា) | អស្សុជ (តុលា) | កក្ដិក (វិច្ឆិកា) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បុណ្យទាក់ទងនឹងកសិកម្ម | | | | | | | | | | | | |
| • ឡើងមាឃ | | | | | | | | | | | | |
| • បុង្គក្រឡាន | | | | | | | | | | | | |
| • ឆ្លងចែត្រ | | | | | | | | | | | | |
| • សុំទឹកភ្លៀង | | | | | | | | | | | | |
| • បុណ្យព្រះខែ ឬអកព្រះខែ | | | | | | | | | | | | |
| | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បុណ្យភូមិ | | | | | | | | | | | | |
| • ឆាន់សាន/ឆាន់ភូមិ | | | | | | | | | | | | |
| • ដាក់ដំណាក់ទឹកស្រក និង ដាក់ដំណាក់ទឹកឡើង | | | | | | | | | | | | |
| • សម្ពោធភូមិ/ឆាន់ភូមិ | | | | | | | | | | | | |
| • បញ្ចៀសចង្រៃ | | | | | | | | | | | | |
| | | | | | | | | | | | | |
| ពិធីឆ្លងវ័យ | | | | | | | | | | | | |
| • កាត់សក់ បង្កក់ឆ្មប | កិច្ចពិធីនេះពុំមានកាលបរិច្ឆេទជាក់លាក់ទេ គឺអាស្រ័យលើពេលវេលានៃការសម្រាលកូន | | | | | | | | | | | |
| • កោរជុក | | | | | | | | | | | | |
| • បូជាសព | | | | | | | | | | | | |
| • ចម្រើនអាយុ | | | | | | | | | | | | |
| • បួស | | | | | | | | | | | | |
| | | | | | | | | | | | | |
| ពិធីក្នុងគ្រួសារ | | | | | | | | | | | | |
| • កាតគ្រោះ | កិច្ចពិធីនេះពុំមានកាលបរិច្ឆេទជាក់លាក់ទេ គឺអាស្រ័យលើគ្រោះថ្នាក់ សុខទុក្ខរបស់មនុស្សតាមរយៈហោរទាយលេខអត្ត: | | | | | | | | | | | |
| • លៀងមេម៉ត់ | | | | | | | | | | | | |
| | | | | | | | | | | | | |

| ពិធីបុណ្យក្នុងពុទ្ធសាសនា | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| • ចូលបរិវាសកម្ម | | | | | | | | | | | | |
| • មាឃបូជា | | | | | | | | | | | | |
| • ទេសន៍មហាជាតក | | | | | | | | | | | | |
| • វិសាខបូជា | | | | | | | | | | | | |
| • ចូលវស្សា | | | | | | | | | | | | |
| • ចេញវស្សា | | | | | | | | | | | | |

## ១. ពិធីបុណ្យក្នុងបរិបទកសិកម្ម

ស្រូវជាដំណាំកសិកម្មយ៉ាងសំខាន់ក្នុងជីវិតខ្មែរទូទៅដែររាប់តាំងពីកើតរហូតដល់ស្លាប់។ ក្នុងដំណើរ «វដ្តស្រូវ» មានដំណាក់កាលពីរសំខាន់ៗ គឺពេលចាប់ផ្តើមដាំដុះ និងពេលប្រមូលផលរួច ហើយដំណាក់កាលទាំងពីរនេះមានឥទ្ធិពលយ៉ាងខ្លាំងលើការរស់នៅ។ ដូច្នេះហើយ ទើបមានកិច្ចពិធីសំខាន់ៗទាក់ទងនឹងកសិកម្មក្នុងដំណាក់កាលទាំងពីរខាងលើនោះ។ តាមតំបន់នានានៃប្រទេសកម្ពុជា ជួនគេឲ្យសារសំខាន់ទៅលើពេលបើកវដ្ត មានន័យថាបុណ្យធ្វើនៅខែពិសាខ ព្រោះជាពេលចាប់ផ្តើមមានភ្លៀងធ្លាក់ ដូចជានៅតំបន់ប្រាសាទសំបូរព្រៃគុកជាដើម។ ស្រុកខ្លះទៀតគេឲ្យសារសំខាន់ទៅពេលបិទវដ្ត មានន័យថាធ្វើបុណ្យខែដែលការប្រមូលផលរួចរាល់រវាងខែបុស្ស ឬខែមាឃ។ រីឯតំបន់អង្គរវិញ យើងសង្កេតឃើញជាទូទៅថា គេធ្វើទាំងពីរ គឺពិធី «ឆ្លងចេត្រ»នៅពេលចាប់ផ្តើមវដ្ត និងពិធី «ឡើងមាឃ» នៅពេលវដ្តចប់។

## ១.១. ឡើងមាឃ

- **ពេលវេលា៖** *ធ្វើនៅខែមាឃ -ខែផល្គុន (ខែកុម្ភៈ-មីនា)*
- **ទីតាំង៖** *ភូមិរលួស និងភូមិដូនទំ (ឃុំបាគង), ភូមិបង្កោង, ភូមិគីរីមានន្ទ និងភូមិត្នោត (ឃុំអំពិល), ភូមិនគរក្រៅ និងភូមិគោកត្នោត, គោកបេង (សង្កាត់គោកចក), ភូមិក្រវ៉ាន់ (សង្កាត់នគរធំ), ភូមិប្រដាក និងភូមិថ្នល់ត្រង់ (ឃុំព្រះដាក់), ភូមិសាលាក្រវ៉ាន់ (ឃុំរំចេក), ភូមិក្រសាំងរលើង (សង្កាត់សៀមរាប), ភូមិភ្នំក្រោម (សង្កាត់ចុងឃ្នៀស), ភូមិស្រែចង្ហុត (ឃុំរុនតាឯក), ភូមិដូនឪ, ភូមិតាប្រុក និងភូមិលាងដៃ (ឃុំលាងដៃ)។*

- **ពិពណ៌នា៖**

*ពិធី«ឡើងមាឃ» ជាពិធីឡើងអ្នកតា ត្បិតគេនិយមធ្វើនៅក្នុងខែមាឃ ជាពិសេសថ្ងៃ៣កើត ខែមាឃ បើទោះជាឃ្លាតបន្តិចក្តីក៏ច្រើនតែធ្វើនៅខែនេះ។ ពិធីឡើងមាឃនេះធ្វើនៅតាមខ្ទមអ្នកតា ឬសាលាឆាន់ក្នុងភូមិ។ ខែមាឃ ជាខែដែលការប្រមូលផលស្រូវបានបញ្ចប់រួចរាល់ទាំងស្រុង ពោលគឺជាការបិទបញ្ចប់វដ្តស្រូវនៃឆ្នាំនោះ។ ជាទូទៅភូមិនៅតំបន់អង្គរមួយចំនួនធ្វើពិធីឡើងមាឃនៅខ្ទមអ្នកតាតែមួយល្ងាចប៉ុណ្ណោះ។ ដោយនៅល្ងាចនោះ អ្នកភូមិធ្វើនំបញ្ចុកតាមផ្ទះរៀងៗខ្លួន រួចយកទៅប្រជុំគ្នានៅមុខខ្ទមអ្នកតា ឯភូមិខ្លះទៀតធ្វើរយៈពេលមួយយប់មួយថ្ងៃ។ ពិធីគឺមានបញ្ចូលអ្នកតា និងមានភ្លេងមេមត់យ៉ាងអធិកអធមផង។ ភូមិខ្លះដូចជាភូមិបង្កោងរក្សាទុកត្រពាំងបុរាណដើម្បីចាប់ត្រីយកធ្វើម្ហូបថ្ងៃឡើងមាឃ។*



ឡើងមាឃនៅភូមិគោកត្នោត



ឡើងមាឃនៅប្រាសាទវត្តអាធ្វារ



ឡើងមាឃនៅភូមិនគរក្រៅ



ឡើងមាឃនៅភូមិបង្កោង



ឡើងមាឃនៅភូមិបង្កោង

## ១.២. ប្ុងក្រាឡាន

- **ពេលវេលា៖** *ធ្វើនៅខែផល្គុន -ខែចេត្រ (ខែមេសា)*
- **ទីតាំង៖** *ភូមិនគរក្រៅ (សង្កាត់គោកចក) និងភូមិលាងដៃ (ឃុំលាងដៃ)*
- **ពិពណ៌នា៖**

*ប្ុងក្រឡាន ជាពិធីមួយមើលទៅហាក់ដូចជាទាក់ទងនឹងពុទ្ធសាសនាខ្លាំង ជាពិសេសពាក់ព័ន្ធនឹងការឧទ្ទិសមគ្គផល។ ប៉ុន្តែបើមើលទៅលើរដូវកាលដែលគេប្រារព្ធវិញ ឃើញថាទាក់ទងនឹងកសិកម្មច្រើនជាងជ្បិតជម្មតានៅខែបុស្សគេតែងច្រូតកាត់រួចរាល់ ហើយមានបុណ្យផ្សេងៗទៀតដែលទាក់ទងនឹងដំណាំស្រូវជាពិសេសដូចជាបុណ្យពូនភ្នំស្រូវជាដើម ដែលទីបំផុតទៅគេយកស្រូវនោះទៅប្រគេនព្រះសង្ឃដូចគ្នា។ បុណ្យប្ុងក្រឡាន គឺជាឧទាហរណ៍មួយដែលជាបុណ្យទាក់ទងនឹងកសិកម្មសុទ្ធសាធ ប៉ុន្តែនៅតែមានកិច្ចក្នុងពុទ្ធសាសនានៅលាយឡំជាមួយដែរ។*





 

*បុណ្យក្រឡាននៅភូមិនគរក្រៅ*

## ១.៣. ឆ្លងចេត្រ

- **ពេលវេលា៖** *ធ្វើនៅខែចេត្រ -ខែពិសាខ* (*ខែមេសា*)
- **ទីតាំង៖** *ភូមិនគរក្រៅ និងភូមិគោកត្នោត* (*សង្កាត់គោកចក*), *ភូមិរលួស* (*ឃុំបាគង*), *ភូមិគោកឫស្សី គោកឫស្សី* (*ឃុំបល្ល័ង្ក*), *ភូមិស្រែចង្ហូត* (*ឃុំរុនតាឯក*), *ភូមិប្រដាក់*, *ភូមិថ្នល់ត្រង់* (*ឃុំព្រះដាក់*), *ភូមិត្បែង* (*ឃុំត្បែង*), *ភូមិដីក្រហម* (*ឃុំកំពង់ភ្លុក*)
- **ពិពណ៌នា៖**

នៅតំបន់អង្គរ ក្រោយពីចូលឆ្នាំហើយប្រមាណមួយ ឬពីរអាទិត្យ យើងសង្កេតឃើញអ្នកស្រុកតែងធ្វើពិធីបុណ្យម៉្យាងហៅថា «ឆ្លងចេត្រ»។ ន័យពិតប្រាកដរបស់ពិធីនេះ គឺឆ្លងផុតពីខែចេត្រចូលទៅខែពិសាខដែល ជាខែភ្លៀងចាប់ផ្ដើមធ្លាក់ និងជាខែដែលអាចចាប់ភ្ជួររាស់បាន ពោលគឺជា "រដូវស្រូវ" ឬជា "រដូវ" ធ្វើស្រែ។ ភូមិខ្លះធ្វើនៅសាលាឆាន់ក្នុងភូមិ ខ្លះទៀតធ្វើរួមគ្នានៅនឹងវត្ត។



ឆ្លងចេត្រនៅភូមិត្បែង



ឆ្លងចេត្រនៅភូមិភូមិគោកឫស្សី



ឆ្វង់ចេត្រនៅភូមិភូមិគោកឫស្សី








*ធ្វងចេត្រនៅវត្តប្រាសាទបាគង*

## ១.៤. សុំទឹកភ្លៀង

- **ពេលវេលា៖** *ធ្វើនៅខែពិសាខ-ខែអាសាឍ (ខែឧសភា-កក្កដា)*
- **ទីតាំង៖** *ភូមិនគរក្រៅ, ភូមិគោកត្នោត (សង្កាត់គោកចក), ភូមិរលួស (ឃុំបាគង), ភូមិគោកឫស្សី (ឃុំបល្ល័ង្ក), ភូមិស្រែចង្ហូត (ឃុំរុនតាឯក), ភូមិប្រដាក់, ភូមិថ្នល់បណ្ដោយ, ភូមិតាត្រៃ (ឃុំព្រះដាក់), ភូមិត្បែង (ឃុំត្បែង)*

- **ពិពណ៌នា៖**

អ្នកស្រុកអង្គរនៅតែពឹងផ្អែកលើទឹកភ្លៀងដើម្បីធ្វើស្រែ ចម្ការ។ នៅរដូវវស្សា ពេលខ្លះភ្លៀងធ្លាក់ពុំត្រូវតាមពេលពេលវេលា ពេលខ្លះរាំងភ្លៀងទឹកមិនគ្រប់គ្រាន់  ពេលខ្លះភ្លៀងធ្លាក់ច្រើនពេកធ្វើឲ្យសំណាបរលួយខូចក៏មាន  ទាំងនេះហើយជាកង្វល់យ៉ាងធំរបស់អ្នកស្រុក។ នៅដើមរដូវវស្សាជាពេលដែលភ្លៀងត្រូវធ្លាក់ហើយ ប៉ុន្តែនៅបន្តរាំងស្ងួតអូសបន្លាយយូរទៅទៀតអ្នកស្រុកតែងធ្វើពិធីសុំទឹកភ្លៀង។ ពិធីសុំទឹកភ្លៀងនេះ ធ្វើខុសគ្នាពីភូមិទៅភូមិមួយហើយជាពិធីទាក់ទងនឹងជំនឿជីវចលតែប៉ុណ្ណោះ តែយ៉ាងណាក៏មានកិច្ចក្នុងពុទ្ធសាសនាខ្លះដែរ ដូចជានិមន្តព្រះសង្ឃចម្រើនព្រះបរិត្តជាដើម។ ជាទូទៅគេច្រើនធ្វើនៅប្រាសាទដែលបង្ហាញពីទំនាក់ទំនងជិតស្និទ្ធរវាងបុរាណដ្ឋាននិងសហគមន៍មនុស្សជុំវិញ។


ពិធីសុំទឹកភ្លៀងនៅប្រាសាទលាក់នាងខាងជើងភ្នំបូក


ពិធីសុំទឹកភ្លៀងនៅប្រាសាទមេបុណ្យខាងកើត

 

*ពិធីសុំទឹកភ្លៀងនៅប្រាសាទនាគព័ន្ធ*

## ១.៥. បុណ្យព្រះខែ, អកព្រះខែ

- **ពេលវេលា៖** *ធ្វើនៅខែកត្តិក (ខែវិច្ឆិកា)*
- **ទីតាំង៖** *វត្តត្រាច (ភូមិព្រុំកុដិ ឃុំបាល័ង្ក), វត្តព្រះធាតុ (ភូមិខ្វាវ ឃុំខ្វាវ), ភូមិបាគង និងភូមិលលៃ (ឃុំបាគង), ភូមិនគរក្រៅ និងវត្តដំរីសសែនជ័យ (ភូមិនគរក្រៅ សង្កាត់គោកចក)*
- **ពិពណ៌នា៖**

*ពិធីបុណ្យព្រះខែ អកព្រះខែដែលអ្នកស្រុករស់នៅតំបន់អង្គរតែងតែធ្វើនៅតាមវត្តអារាម គឺធ្វើនៅចំពេលស្រូវចាប់ផ្តើមទុំ*

ត្រៀមនឹងច្រូតកាត់។ ពិធីនេះក៏ទាក់ទងនឹងបរិមាណទឹកភ្លៀង និងភោគផលស្រូវដែលនឹងបាននៅឆ្នាំបន្ទាប់។ពិធីធ្វើនៅពេលយប់ពេលព្រះចន្ទ្រដើរចំពីលើ។ គេអកគ្នាទៅមកក្នុងន័យ "សេសសល់ ហូរហៀរ" និង "សម្បូណ៌ សប្បាយ" ឥតខ្វះខាត។ ដើម្បីបានអំបុកទាល់តែមានស្រូវថ្មី ហើយដើម្បីមានស្រូវថ្មី ទាល់តែទើបនឹងច្រូតហើយមិនយូរប៉ុន្មាន។ យប់នោះសោតគេមានកិច្ច "សម្រក់ទៀន" ដើម្បីផ្សងមើលទៅថា ឆ្នាំក្រោយដំណើរភ្លៀងដូចម្ដេចដែរ។



អកព្រះខែនៅវត្តត្រាច



អកព្រះខែនៅវត្តព្រះជាតុ

 

*អកព្រះខែនៅវត្តប្រាសាទបាគង*

## ២. បុណ្យភូមិ

*ជាធម្មតាអ្នកភូមិតែងរៀបចំធ្វើពិធីបុណ្យភូមិរាល់ឆ្នាំក្រោយពេលធ្វើស្រែចម្ការ និងប្រមូលផលរួច ឬនៅពេលបញ្ចៀសជម្ងឺ ឬចង្រៃឧតត្បាតផ្សេងៗពីភូមិស្រុក។ មានពិធីបុណ្យជាច្រើនទាក់ទងនឹងបុណ្យភូមិដែលអ្នកស្រុកអង្គរ និងអ្នកស្រុករស់នៅជាប់មាត់ទន្លេសាបតែងប្រតិបត្តិជារៀងរាល់ឆ្នាំ ដូចជា៖ ឆាន់សាន, សម្ពោធភូមិ/ឆាន់ភូមិ និងបុណ្យបញ្ជូនទូកលេង។ ពិធីបុណ្យនីមួយៗតែងតែមានអ្នកដឹកនាំធ្វើកិច្ចផ្សេងៗទៅតាមលំដាប់លំដោយ។*

## ២.១. ឆាន់ភូមិ/ឆាន់សាន

**ពេលវេលា៖** *ធ្វើនៅខែមាឃ (ខែកុម្ភៈ)*

- **ទីតាំង៖** *ភូមិដីក្រហម និងភូមិត្នោតកំបុត (ឃុំកំពង់ក្ទុក)*
- **ពិពណ៌នា៖**

*អ្នកកំពង់ក្ទុក គេហៅថាបុណ្យ «ឆាន់សាន» ឬ «ឆាន់ភូមិ» ដែលគេធ្វើនៅខែមាឃ។ ក្នុងឃុំកំពង់ក្ទុក អ្នកស្រុកធ្វើតាមភូមិរៀងៗខ្លួនក្នុងថ្ងៃតែមួយ។ ការហៅបុណ្យឆាន់សានទំនងហៅភ្ជាប់ឈ្មោះ«សាន»ដែលជាឈ្មោះអ្នកតាមួយនៅក្នុងភូមិត្នោតកំបុត។ នៅពេលធ្វើកិច្ចពិធីបុណ្យប្រចាំឆ្នាំ អ្នកភូមិត្នោតកំបុត ភូមិដីក្រហម និងភូមិគោកក្តុលរៀបចំកិច្ចពិធីនៅក្បែរខ្ទមអ្នកតាប្រចាំភូមិរៀងៗខ្លួន។*

*គោលបំណងធំនៃបុណ្យឆាន់សាន ឬឆាន់ភូមិនេះ គឺដើម្បីសុំក្តីសុខសប្បាយសម្រាប់ភូមិដ្ឋាន សុំម្ចាស់ទឹកម្ចាស់ដីដែលខ្លួនបានជីកកាយធ្វើស្រែះចិញ្ចឹមត្រី និងកាពារត្រីកុំឲ្យងាប់។ ក្នុងពិធីបុណ្យនេះ ក៏មាននិមន្តព្រះសង្ឃឆាន់ពេលព្រឹក និងពេលថ្ងៃត្រង់ រួចឧទ្ទិសកុសលដល់អ្នកដែលបានចែកស្ថាន។ ក្នុងថ្ងៃបុណ្យឆាន់សានក៏ធ្វើបុណ្យដំណាក់ដើម្បីបញ្ចូលរូបអស់លោក និងបញ្ជូនអស់លោកទៅទន្លេដើម្បីបញ្ចៀសជម្ងឺពីអ្នកស្រុក។*













*ឆាន់សាន ឬបុណ្យឆាន់ភូមិនៅកំពង់ភ្លុក*

## ២.២. ដាក់ដំណាក់ទឹកស្រក និងដាក់ដំណាក់ទឹកឡើង

- **ពេលវេលា៖** *ធ្វើនៅខែមាឃ (ខែកុម្ភៈ) និងខែអាសាឍ (កក្កដា)*
- **ទីតាំង៖** *ភូមិដីក្រហម, ភូមិត្នោតកំបុត និងភូមិគោកក្តុល (ឃុំកំពង់ភ្លុក)*
- **ពិពណ៌នា៖**

*បុណ្យដាក់ដំណាក់នៅខែទឹកស្រក និងខែទឹកឡើងអាចធ្វើនៅខែខ្នើត ឬខែរនោចក៏បានឲ្យតែថ្ងៃឡើងពេញចំថ្ងៃសុក្រសម្រាប់ដាក់ដំណាក់ខែទឹកស្រក ឯបុណ្យដាក់ដំណាក់ខែទឹកឡើងវិញត្រូវធ្វើឲ្យចំថ្ងៃសៅរ៍។ កាលបើរើសថ្ងៃសម្រាប់ពិធីដាក់ដំណាក់ខែមាឃ (ដាក់*

ដំណាក់ខែទឹកស្រក) ត្រូវនឹងខែកុម្ភៈបានហើយ គេនឹងរើសយកថ្ងៃធាន់ភូមិនៅថ្ងៃនោះដែរតែម្តងដោយមានរយៈពេលពីរថ្ងៃ។ អ្នកស្រុកក៏បានបញ្ចូលបុណ្យឡើងមាឃនៅក្នុងថ្ងៃនេះដែរ ប៉ុន្តែរយៈពេល៣ឆ្នាំទើបគេរៀបចំពិធីនេះម្តង។ រីឯបុណ្យដាក់ដំណាក់ខែទឹកឡើងធ្វើតែមួយថ្ងៃតែត្រូវរើសឲ្យចំថ្ងៃសៅរ៍នៃខែប.សាឍ (ខែកក្កដា) ព្រោះថ្ងៃសៅរ៍ជាថ្ងៃសែនគ្រូធំ ជាថ្ងៃដែល«ខ្មោច អារក្ស អ្នកតាចូលចិត្តទទួលគ្រឿងសំណែន ថ្ងៃក្រៅពីនេះមិនសូវទទួល ឬទទួលដោយទ្រាំទ្រឹស្ត»។

បុណ្យដាក់ដំណាក់ដែលធ្វើក្នុងពេលខាងលើនេះពាក់ព័ន្ធនឹងកម្ពស់ទឹក បរិស្ថានធម្មជាតិ ទិន្នផលត្រី និងការបញ្ចៀសជម្ងឺរាតត្បាតក្នុងភូមិ។ ពោលគឺនៅខែមាឃជាពេលកំពុងពេញរកត្រី ខែចេត្រជាពេលទឹកទន្លេស្រកខ្លាំង និងខែអាសាឍជាពេលដែលទឹកទន្លេចាប់ផ្តើមឡើង។ នៅខែទឹកឡើងរវាងខែមិថុនា ឬកក្កដាដល់ខែកញ្ញា ឬតុលា នៅទន្លេតែងមានភ្លៀងខ្យល់បោកបក់ខ្លាំងដោយបង្កគ្រោះថ្នាក់ដល់អ្នកចេញនេសាទ ហើយរកត្រីក៏ពុំសូវបាន។ ពិធីទាំងអស់នេះដើរស្របនឹងវដ្តជីវិតត្រីផង និងវដ្តនៃការនេសាទផង។





*សង្សៀកដាក់ដំណាក់នាទឹកឡើង*












ហែសង្ឃ្រឹកពេលបុណ្យដំណាក់ពេលទឹកស្រក និងពេលទឹកឡើង

## ២.៣. សម្ពោធភូមិ

- **ពេលវេលា៖** ធ្វើនៅខែផល្គុន-ចេត្រ (ខែមីនា-មេសា)
- **ទីតាំង៖** ភូមិលាងដៃ (ឃុំលាងដៃ), ភូមិព្រះដាក់ (ឃុំព្រះដាក់), ភូមិស្រះស្រង់ជើង (សង្កាត់នគរធំ) និងភូមិចំបក់ (ឃុំរលួស)
- **ពិពណ៌នា៖**

*កិច្ចដែលទាក់ទងនឹងផ្ចិតភូមិគេតែងហៅថា "សម្ពោធ" មិនថាកិច្ចជាប្រក្រតី (ដាច់អាណត្តិភូមិ) ធ្វើដោយមានគ្រោះឧតត្បាតចង្រៃអ្វីមួយកើតឡើងក្នុងភូមិ, បង្កើតតែងតាំងព្រះភូមិមុនដំបូង ក៏តម្រូវឲ្យរៀបចំបង្គក់ភូមិទាំងមូលជាមុនសិន គឺព្រះសង្ឃនិមន្តសូត្របញ្ចៀសចង្រៃតាមផ្ទះឥតមានរំលងផ្ទះណាមួយឡើយ។ ការបង្កើតតែងតាំងព្រះភូមិមុនដំបូងគេនោះឯងដែលធំជាងគេបំផុត ព្រោះមុននឹងយកបង្គោលថ្មីមកដាំឲ្យទៅជាផ្ចិតភូមិនោះ ត្រូវធ្វើកិច្ចវែងឆ្ងាយណាស់ ដូចជាហៅព្រលឹង បង្វិលពពិល ចងអំបោះឲ្យបង្គោលដើម្បីឲ្យបង្គោលនោះមានជីវិត ហើយនៅពេលបញ្ចុះនោះទៀតសោត គេសូត្រតែបញ្ចុះគាថានៅបាតដីទៀតផង។ ដូច្នេះហើយបានជាអ្នកខ្លះហៅផ្ចិតភូមិនេះថា "អាថាន់"។ ដែលហៅថា «ព្រះភូមិ » គឺចំណុចកណ្ដាលនៃភូមិដែលគេដាំបង្គោលមួយ ឬប្រាំ ហើយដែលគេចាត់ទុកថាជា «ផ្ចិតភូមិ »នេះឯង។ ពាក្យ «សម្ពោធ» ទីនេះសំដៅលើការធ្វើឲ្យថ្មីឡើងវិញ ដូចនឹងភូមិករ ឬលោកទាំងមូលវិលពីកលិយុគមកក្ឫតយុគវិញ។*



ដាំបង្គោលថ្មីធ្វើជាផ្ចិតភូមិ



ផ្ចិតភូមិ ឬព្រះភូមិ



ព្រះសង្ឃនិមន្តសូត្របញ្ចៀសចង្រៃតាមផ្ទះក្នុងថ្ងៃសម្ពោធភូមិ



សម្ពោធវត្តប្រាសាទបាគងដោយយកប្រាសាទបាគងធ្វើជាផ្ចិតភូមិ

## ២.៤. បុណ្យបញ្ជូន

- **ពេលវេលា៖** *ធ្វើនៅខែស្រាពណ៍ (ខែសីហា)*
- **ទីតាំង៖** *ភូមិចំបក់ (ឃុំរលួស)*
- **ពិពណ៌នា៖**

*នៅពេលរដូវទឹកទន្លេឡើង ពោលនៅរវាងខែសីហា អ្នកភូមិចំបក់ត្រូវធ្វើពិធីបញ្ជូនដើម្បី បញ្ចៀសជម្ងឺ ឬចង្រៃឧតត្បាតផ្សេងៗពីភូមិស្រុកតាមទិសខាងជើង។ ចង្រៃឧតត្បាតនោះកើតឡើងពីអមនុស្សដែលគេស្គាល់ថា«ស្រ្កាច»។ អ្នកភូមិបានរៀបសង្ឃឹកធំល្មមមានដាក់សំណែនផ្សេងៗដូចជា៖ ក្បាលជ្រូក មាន់ស្ងោរ ម្ហូបម្ហា ចំណីចំណុក បាយស្រី ពៃ ទៀន ធូបនៅខាងក្នុងនោះ។ ពេលរសៀល អ្នកភូមិនាំគ្នាហែសង្ឃឹកចេញពីសាលាឆាន់ ឬផ្ទះឥតឲ្យមើលក្រោយសំដៅទៅប្រាសាទព្រៃមន្ទីរ ដោយហែកាត់តាមផ្លូវក្នុងភូមិ ដើម្បីឲ្យអ្នកភូមិចំបក់ទាំងអស់អាចចូលរួមជាប្រាក់កាស និងស្បូះអង្ករទៅលើសង្ឃឹក។ ពេលមកដល់ប្រាសាទព្រៃមន្ទីរ គេធ្វើកិច្ចផ្សេងៗដូចជាចូលរូប និងសែនសំណែននៅមុខផ្តែរប្រាសាទ។ ពេលរួចរាល់កិច្ចហើយ គេដង្ហែសង្ឃឹកទៅទុកចោលនៅជុបព្រៃខាងកើតប្រាសាទបាគង។ ពីមុនមក តាមភូមិនីមួយៗនៅស្រុកប្រាសាទបាគងក៏មានពិធីនេះដែរ។ ភូមិខាងក្រោមបញ្ជូនមកខាងលើ អ្នកភូមិខាងលើត្រូវធ្វើពិធីបញ្ជូនសង្ឃឹកនោះបន្តទៅខាងជើងបន្តទៀត។*




AMERICAN









កិច្ចបញ្ជូនទៅភូមិចំបក់ ឃុំរលួស ស្រុកប្រាសាទបាគង

## ៣. ពិធីឆ្លងវ័យ

"ពិធីឆ្លងវ័យ" សំដៅលើកិច្ចពិធីដែលទាក់ទងនឹងដំណាក់កាលនៃជីវិតមនុស្សតាំងពីកើតដល់ស្លាប់ តាមរយៈការរៀបចំ"ពិធី" ដែលសង្គមទាមទារ ឬតម្រូវទៅលើបុគ្គល ហើយសម្រាប់បុគ្គលដដែលនោះផង។ នៅប្រទេសកម្ពុជា ក៏ដូចជានៅតំបន់អង្គរឃើញថាឆ្លងវ័យមានដល់ទៅ៨ដំណាក់កាលៈ ដំណាក់ទី១ គឺពិធីទាក់ទងនឹងកំណើតមនុស្ស។ ដំណាក់ទី២ គឺការប្រុងប្រៀបខ្លួនទៅក្នុងវ័យពេញវ័យ។ លុះវ័យពេញហើយ ក៏មានពិធីពីរទៀតយ៉ាងសំខាន់ តែដំណើរ និងន័យរបស់ពិធីនោះពុំដូចគ្នាទេ។ ប្រុសមានពិធីសម្រាប់ប្រុស ឯស្រីមានពិធីផ្សេងរបស់ខ្លួន។ នេះរាប់ថាមានពិធី៤ហើយ។ ពិធីទី៥គឺមង្គលការ។ ចំណែកឯពិធីទី៦ទាក់ទងតែនឹងស្រីប៉ុណ្ណោះ គឺការឆ្លងទន្លេ

*ជាពិសេសឆ្លងទន្លេជាលើកដំបូង ត្បិតដំណាក់នោះគឺស្រីឆ្លងពីភាពជាកញ្ញាមកភាពជាមាតា។ ឯពិធីចម្រើនអាយុជាពិធីទី៧។ ដំណាក់កាលចុងក្រោយនៃជីវិតជាពិធីទី៨ គឺពិធីដែលទាក់ទងនឹងសព។ នៅទីនេះ យើងលើកយកតែពិធីដែលសព្វថ្ងៃឃើញមាននៅតំបន់អង្គរមកបង្ហាញតែប៉ុណ្ណោះ។*

## ៣.១. កាត់សក់បង្កក់ធ្មប

- **ពេលវេលា៖** *មិនកំណត់ពេលវេលា*
- **ទីតាំង៖** *មាននៅតាមភូមិមួយចំនួនក្នុងតំបន់អង្គរ*
- **ពិពណ៌នា៖**

*ពិធី «កាត់សក់បង្កក់ធ្មប ឬទម្លាក់ជើងក្រាន» គឺគេធ្វើឲ្យមនុស្ស៣នាក់៖ កាត់សក់ គឺកាត់ឲ្យទារក, បង្កក់ធ្មប គឺជាកិច្ចធ្វើជូនធ្មបដើម្បីសូមខមាទោសដោយសារគាត់បាន "កាន់ពោះ កាន់ពុង" ស្រីជាម្ដាយពេលត្រូវបង្កើតកូននោះ និងសម្រាប់ម្ដាយដែលនៅអាំងភ្លើងជើងក្រាននោះ។ ពិធីនេះ គេធ្វើយ៉ាងឆាប់៣ថ្ងៃក្រោយពីទារកកើតមក ឬក៏មួយ មួយអាទិត្យក្រោយមកទើបធ្វើក៏មានដែរ ព្រោះសព្វថ្ងៃភាគច្រើនគេទៅកើតនៅតាមមណ្ឌលសុខភាព ដូច្នេះហើយពេលត្រឡប់មកផ្ទះវិញទើបរៀបចំធ្វើពិធី ទោះបីពុំបង្កើតដោយធ្មបបុរាណក៏ដោយ។*

*គោលបំណងនៃការៀបចំពិធីនេះ គឺកាត់សក់កំណើតទារក ដែលគេហៅថា "សក់ព្រៃ" ដើម្បីផ្ដាច់ក្មេងនោះកុំឱ្យជំពាក់ជំពិននឹងវិស័យព្រៃដែលជាពិភពខ្មោច។ ជាពិសេសធ្វើឱ្យដាច់ចេញពី "ម្ដាយដើម" ពោលគឺម្ដាយរបស់វានៅពីជាតិមុនៗ។ ចំណែកបង្កក់ធ្មបមានន័យថា លាងសម្អាត ជម្រះធ្មបនោះឱ្យផុតពីមន្ទិលដែលជាប់ប្រឡាក់ប្រឡូស ដោយសារគាត់បានប៉ះពាល់នឹងឈាមជ័រ ពោះពុងស្រីជា*

ម្តាយពេលឆ្លងទន្លេនោះ។ រីឯទម្លាក់ដើងក្រាន ពន្លត់ភ្លើងដើងក្រានដែលម្តាយអាំង ដើម្បីបញ្ចប់ត្រណមផ្សេងៗដែលកាន់ក្នុងរយៈពេលអាំងភ្លើង។ នៅក្នុងពិធីនេះ មានកិច្ចមួយ គឺគេ "ដាប់មាត់" ឱ្យទារកនោះ ដោយយកពន្លាកនិង អន្ទូងមកឧបកិច្ចធ្វើកាយវិការ ដោយនិយាយប្រដៃប្រដៅទារកឱ្យទុកមាត់និយាយតែសម្តីល្អ, មានន័យ, ហាមមិនឱ្យថ្ងៃក្រោយមាត់នោះនិយាយដើមគេជាអាទ៏។ល។ ពិធីកាត់សក់ បង្កក់ធ្មប ឬទម្លាក់ដើងក្រាននេះ ក៏មានព្រះសង្ឃ និងអាចារ្យជាអ្នករៀបចំកិច្ចផ្សេងៗ។







ពិធីកាត់សក់ បង្កក់ធ្មប ឬទម្លាក់ជើងក្រាននៅភូមិស្ពានជ្រាវ

## ៣.២. គោរជុក

- **ពេលវេលា៖** ធ្វើនៅខែមាឃ -ខែផល្គុន (ខែកុម្ភៈ-មីនា)
- **ទីតាំង៖** ភូមិចាន់ស (ឃុំចាន់ស), ភូមិតានី (ឃុំរុនតាឯក), ភូមិត្នោតជ្រុំ និងភូមិប្រាសាទចារ្យ (ឃុំដូនកែវ)
- **ពិពណ៌នា៖**

«កោរជុក» ឬ «កោរកំប៉ោយ» ជាពិធីឆ្លងវ័យមួយក្នុងចំណោមពិធីឆ្លងវ័យដទៃទៀត។ ពិធីនេះជាការរៀបចំឲ្យសាមីខ្លួនត្រៀមចូលក្នុងភាពពេញវ័យ។ ដូច្នេះហើយបានជាពិធីនេះត្រូវធ្វើមុនក្មេងប្រុស និងក្មេងស្រីពេញវ័យ ដែលជាធម្មតាត្រូវធ្វើចាប់ពីអាយុ៩ ទៅ១៣ ឆ្នាំ។ សព្វថ្ងៃ ទំនៀមកោជុកនៅតាមភូមិមួយចំនួនក្នុងតំបន់អង្គរពុំសូវមានទៀតទេ ទោះជាពិធីនេះជាទំនៀមធ្លាប់ធ្វើ ដើម្បីជាមង្គលដល់កូនក្នុងវ័យនេះក្តី។





កោរជុកនៅភូមិតាត្រៃ





ការផ្ដុកនៅភូមិតាត្រៃ







ការផុកនៅភូមិតានី (រុនតាឯក)

## ៣.៣. បូជាសព

- **ពេលវេលា៖** *ធ្វើនៅខែមាឃ -ផល្គុន (ខែកុម្ភៈ-មីនា)*
- **ទីតាំង៖** *ភូមិលាងដៃ, ភូមិភ្នង់ (ឃុំលាងដៃ), ភូមិគោកត្រាច (ឃុំបាគង), ភូមិគោកបេង (សង្កាត់គោកចក), ភូមិក្រសាំងរលើង (សង្កាត់សៀមរាប)*
- **ពិពណ៌នា៖**

*អ្នកនៅខាងជើងតំបន់អង្គរ គេពុំយកសពដែលបានស្លាប់មួយថ្ងៃ ឬពីរថ្ងៃទៅបូជានោះទេ ពោលគឺ ក្រោយធ្វើបុណ្យបាន១ថ្ងៃ ឬ២ថ្ងៃក្រោយស្លាប់ គេយកសពទៅកប់នៅតាមគោកខ្មោច ដែលជាទីទួល ឬព្រៃកប់ខ្មោចរួមរបស់អ្នកស្រុក «ឲ្យព្រះធរណីឱប» ដើម្បីឲ្យដី និងទឹករំលាយរាងកាយជាមុនសិន។ ក្រោយកប់បាន២ឆ្នាំ ទៅ៣ឆ្នាំ ឬ៥ឆ្នាំ ឬយូរជាងនេះ ទើបគេគាស់យកឆ្អឹង ហៅថា «លើកសព» ដែលរាងកាយរលេះរលួយអស់មកបូជា ដោយអ្នកភូមិខ្លះហៅថា ពិធីបូជាសព, អុជសព, បញ្ចេះបុគ្គល ឬចម្រើនភ្លើង ដើម្បីឲ្យភ្លើង និងខ្យល់រំលាយបង្ហើយ ទើបចាត់ទុកថាបុណ្យសពបានចប់សព្វគ្រប់។ កិច្ចពិធីក្នុងដំណាក់កាលទាំងពីរខាងលើនេះ បង្ហាញថា រូបរាងកាយយើងម្នាក់ៗផ្គុំឡើងដោយធាតុដី ទឹក ភ្លើង និងខ្យល់ ហើយរលាយទៅវិញក៏ដោយធាតុទាំងបួននេះដែរ។*

*ពិធីនេះច្រើនធ្វើនៅខែមាឃ ឬផល្គុណ ហើយមានភាពអធិកអធមណាស់ ពិសេសពេលគេធ្វើបុណ្យចូលគ្នាជាមួយព្រះសពព្រះថៅអធិការវត្តណាមួយ។ ក្រៅពីនេះ គ្រួសារខ្លះដែលមានធនធានច្រើន គេអាចធ្វើជាលក្ខណៈគ្រួសារបាន ប៉ុន្តែពេលខ្លះក៏មានអ្នកភូមិសុំចូលចូលធ្វើពិធីនេះជាមួយបានដែរ។ ទីចម្រើនភ្លើង គេធ្វើមេរុខ្ពស់សន្ធឹមកណ្តាលវាលស្រែ មានធ្វើរោងបុណ្យនៅខាងត្បូង និងរានរណ្តាប់ផ្សេងៗដែលតំណាងឲ្យស្ថានសួគ៌ដែលគេនិម្មិតនៅលើដី ព្រោះគំនិតនៃពិធីនេះធ្វើយ៉ាងណា គឺរកពេលវេលាឲ្យអ្នកដែលបានស្លាប់ហើយទៅចាប់ជាតិទៀតបាន។ ក្នុងពិធីចម្រើនភ្លើងអាចមានខ្មោច ឬបុគ្គលលើសពី១ ត្បិតនេះជាឱកាសល្អដែលមនុស្សធ្វើរួមគ្នានាំ*

ឲ្យការចំណាយតិច។ ពិធីនេះមានកិច្ចច្រើនដំណាក់កាលណាស់ដែលរៀបរាប់ចោះៗដូចជា កិច្ចលួចសព កិច្ចរំកិលសព កិច្ចបូជាសព កិច្ចប្រែរូប និងបំពេរធាតុទើបបូជារួចៗល។ ទាំងនេះបង្ហាញច្បាស់អំពីជំនឿលើការចាប់ជាតិ។ កិច្ចចុងក្រោយគឺយកធាតុទៅបញ្ចុះនៅតាមចេតិយក្នុងវត្ត ឬនៅតាមគោកដែលជាព្រៃបញ្ចុះធាតុ។











*ពិធីបូជាសពនៅតំបន់អង្គរ*

## ៣.៤. ចម្រើនអាយុ

- **ពេលវេលា៖** *ធ្វើនៅខែផល្គុន-ពិសាខ (ខែមីនា-មេសា)*
- **ទីតាំង៖** *ភូមិត្នោត(ឃុំអំពិល), ភូមិគោកបេង (សង្កាត់គោកចក), ភូមិគោកត្រាច (ឃុំបាគង), ភូមិក្រសាំងរលើង (សង្កាត់សៀមរាប), មិស្រែចង្ហូត(ឃុំរុនតាឯក), ភូមិថ្នល់បណ្ដោយ (ឃុំព្រះដាក់)*
- **ពិពណ៌នា៖**

*ចម្រើនអាយុជាពាក្យហៅទូទៅចំពោះពិធីបុណ្យមួយចំនួនដែលកូនចៅផ្ទាល់ ញាតិមិត្តជិតឆ្ងាយ ឬសិស្សគណប្រារព្ធពិធីនេះជូន*

សាមីពិធីដែលជាមនុស្សមានវ័យចំណាស់។ ពិធីបុណ្យទាំងនោះមានដូចជា៖ បច្ច័យបួន, ច័ន្ទសុក្រគិរីសូត្រ និងឆាកមហាបង្សុកូល។ នៅតំបន់អង្គរអ្នកស្រុកនិយមធ្វើពិធី «ច័ន្ទសុក្រគិរីសូត្រ» ដែលហៅឈ្មោះតាមគម្ពីរដែលព្រះសង្ឃយកមកសូត្រក្នុងពិធីចម្រើនអាយុនេះ ដែលផ្ទុយពីអ្នករស់នៅភ្នំពេញ ឬអ្នករស់នៅតាម បណ្ដាខេត្តមួយចំនួនទៀត ដែលហៅថា «បុណ្យបច្ច័យបួន»។ នៅតំបន់អង្គរ ពិធីនេះច្រើនធ្វើពីខែផល្គុណដល់ខែពិសាខ។

ន័យទូទៅរបស់ពិធី គឺធ្វើយ៉ាងណាឲ្យម្ចាស់សាមីមានអាយុវែង តាមរយៈការសន្មតថាសាមីពិធីនោះស្លាប់ ដោយគ្របសំពត់សហើយទាញសំពត់សចេញវិញឧបកិច្ចដូចកើតថ្មីម្ដងទៀត គេហៅថាកិច្ចឆាក ឬ«បកស្នព»។ ដូច្នេះហើយបានជាគ្រឿងវណ្ដាប់សំខាន់ត្រូវមានចំនួន១០០ ដូចជាភ្នំខ្សាច់ដែលគេពូនសម្រាប់ពិធី ដើម្បីឲ្យសាមីពិធីមានអាយុវែងត្រូវនឹងពាក្យឲ្យពរថា «សូមឲ្យបានអាយុ១០០»។









បុណ្យច័ន្ទសុក្រគិរីសូត្រនៅភូមិថ្នល់





ច័ន្ទសុក្រគិរីសូត្រនៅវត្តអាធ្វារ និងកិច្ចដុតពុតម្លូសក្នុងពិធីកាត់គ្រោះនៅភូមិគោកឫស្សី



បុណ្យច័ន្ទសុក្រគិរីសូត្រនៅភូមិរលួស









បុណ្យច័ន្ទសុក្រគិរីសូត្រនៅភូមិទ្រាំង

## ៣.៥. បួស

- **ពេលវេលា៖** ធ្វើនៅពិសាខ-អាសាឍ (ខែឧសភា-ខែកក្កដា)
- **ទីតាំង៖** ភូមិនគរក្រៅ (សង្កាត់គោកចក), ភូមិត្នោតជ្រុំ, ភូមិតាកាំ, ភូមិប្រាសាទចារ្យ (ឃុំដូនកែវ), ភូមិលាងដៃ (ឃុំលាងដៃ) ភូមិឪឡោក (ឃុំបាគង)
- **ពិពណ៌នា៖**

«បួស» ដែលក្មេងប្រុសពេញវ័យបួស គឺជាដំណាក់កាលមួយនៃពិធីឆ្លងវ័យ គឺពុំទាក់ទងនឹងការសាងផ្នួស ដោយសារលុះក្នុងព្រះពុទ្ធសាសនានោះទេ។ ប្រុសដែលចូលក្នុងវ័យកម្លោះ គេញែកចេញឲ្យដាច់ពីស្រីដែលចូលក្នុងវ័យក្រមុំ ត្បិតអំណឹះតទៅអ្នកទាំងពីរនេះនៅក្នុងវិស័យផ្សេងស្រឡះពីគ្នា។ ប្រុសដែលនឹងត្រូវជាអ្នករុករក, ជួញប្រែទៅទីជិតឬទីឆ្ងាយជាដើមនោះ ត្រូវមានវិជ្ជាជាមូលដ្ឋានគ្រប់គ្រាន់។ បើកាលណាបើចង់បំពេញវិជ្ជានានា គេត្រូវទៅរៀននៅវត្តដែលមានព្រះសង្ឃជាគ្រូបាធ្យាយ។ ហេតុនេះហើយទើបមានពាក្យចាស់ថា «បួសរៀន»។ ជាទូទៅនៅតំបន់អង្គរ ពិធីបួសនាគច្រើនធ្វើមុនចូលព្រះវស្សា ហើយក្នុងពិធីបំបួសអាចមាននាគតិច ឬច្រើន។







*ពិធីបួសនៅភូមិគោកដូង និងភូមិត្នោតជ្រុំ*

## ៤.ពិធីក្នុងគ្រួសារ

ពិធីប្រចាំគ្រួសារសំដៅលើការរៀបចំពិធីសម្រាប់បុគ្គលណាម្នាក់ក្នុងរង្វង់គ្រួសារជាជាងក្នុងសហគមន៍ ឬអាចនិយាយថាពុំមែនជាកង្វល់សហគមន៍ទាំងមូលទេ។ តែករណីខ្វះជៀសពុំរួច ឬពុំផ្ដាច់ចេញពីសហគមន៍ទាំងស្រុងទេ ត្បិតក្នុងសហគមន៍នីមួយៗនៅតែងប្រាស្រ័យគ្នាទៅមកពុំលែង។ ដូចករណីកាត់គ្រោះ ពេលមានមនុស្សឈឺ គ្រួសារសាច់ញាតិអាចទៅជួបព្រះសង្ឃ ឬអាចារ្យធ្វើតែក្នុងរង្វង់គ្រួសារក៏បាន។ ឯពិធីលៀងមេមត់ក៏ស្រដៀងដូច្នោះដែរ គេអាចធ្វើក្នុងរង្វង់គ្រួសារសាច់ញាតិក៏បាន បើរូបសម្បកនោះឈឺខ្លាំង ឬមានធនធានៗ តែភាគច្រើន ទោះជារូបសម្បករៀងខ្លួនពិតមែន ក៏គេច្រើនធ្វើចូលគ្នានៅរវាងខែមាឃ។

## ៤.១. កាត់គ្រោះ

- **ពេលវេលា៖** *កិច្ចពិធីនេះពុំមានកាលបរិច្ឆេទជាក់លាក់ទេ គឺអាស្រ័យលើការទាយក័ព្វព្រេងសំណាង និងគ្រោះថ្នាក់សុខទុក្ខរបស់មនុស្សតាមរយៈហោរទាយលេខអត្ត:*
- **ទីតាំង៖** *ភូមិរលួសលិច (ឃុំរលួស), ភូមិលលៃ (ឃុំបាគង), ភូមិភូមិគោកឫស្សី (ឃុំបល្ល័ង្ក), ភូមិត្នោត (ឃុំអំពិល), ភូមិត្នោតជ្រុំ (ឃុំដូនកែវ) និងភូមិប្រហ៊ូត (ឃុំល្វា)*
- **ពិពណ៌នា៖**

*នៅពេលដែលគេយល់ថាមានគ្រោះដែលពាក់ព័ន្ធនឹងឆ្នាំកំណើត ព្រមទាំងឆ្នាំបច្ចុប្បន្នដែលនាំអ្នកណាម្នាក់ឈឺនោះ ឬមួយមានគ្រូហោរណាមួយទាយលេខអត្ត:ប្រាប់ឲ្យដឹងថាឆ្នាំនេះនឹង «ដាក់» ដូច្នេះហើយទើប គេតែងតែមានកិច្ចមួយសម្រាប់បញ្ចៀសចង្រៃចេញពីខ្លួន ដែលអ្នករស់នៅតំបន់អង្គរហៅថា «កាត់គ្រោះ»។ ពិធីកាត់គ្រោះពុំតម្រូវឲ្យមានអ្នកចូលរួមច្រើនទេ មានតែជាអ្នកជម្ងឺនិងអ្នកនៅផ្ទះជាមួយគ្នាជួយគ្រូដែលកាត់គ្រោះនោះតែប៉ុណ្ណោះ។ ជួនកាល គេទៅរកព្រះសង្ឃឲ្យកាត់គ្រោះនៅវត្តឲ្យក៏មាន។ កិច្ចពិធីកាត់គ្រោះនេះមានរយៈពេលវែង ដោយគ្រូកាត់គ្រោះត្រូវសូត្របណ្ដេញព្រាយនិងឧបទ្រពចង្រៃអ្វីទាំងអស់ចេញពីខ្លួន ហើយនិងអន្ទងទេពនិករទាំងអម្បាលម៉ានឲ្យមកថែរក្សាសាមីពិធី។*




កាត់គ្រោះនៅភូមិប្រហ៊ូត




កាត់គ្រោះនៅភូមិគោកឫស្សី

  

*កាត់គ្រោះនៅភូមិរលួស*

## ៤.២. លៀងមេមត់

- **ពេលវេលា៖** *ធ្វើនៅខែមាឃ -ផល្គុណ (ខែកុម្ភៈ)*
- **ទីតាំង៖** *ភូមិនគរក្រៅ, (សង្កាត់គោកចក), ភូមិអារក្សស្វាយ (សង្កាត់នគរធំ), ភូមិក្រសាំងរលើង, ភូមិទ្រៀក (សង្កាត់សៀមរាប), ភូមិភូមិថ្នល់បាក់ (ឃុំអំពិល), ភូមិត្នង់ (ឃុំលាងដៃ), ភូមិក្បាលដំរី (ឃុំរើស)*

• **ពិពណ៌នា៖**

លៀងមេមត់ គេចំណាំធ្វើនៅខែមាឃ ឬអាចធ្វើក្នុងបរិបទពិសេសណាមួយនៅពេលមានរូបមេមត់ ឬ«សម្បក» ឈឺធ្ងន់ ដោយសារអមនុស្សធ្វើឲ្យរូបស្នងនោះឈឺ។ ហេតុនេះ ដើម្បីដោះស្រាយ និងជៀសវាងកុំឲ្យឈឺ ត្រូវលៀងមេមត់ក្នុងមួយឆ្នាំ ឬពីរឆ្នាំម្ដង។ ជាទូទៅស្រុកឬតំបន់ខ្លះគេហៅថា«អារក្ស» ក៏ប៉ុន្តែនៅតំបន់អង្គរ គេនិយមហៅ «មេមត់» មិនសូវឮប្រើពាក្យអារក្សទេ។ ដូច្នេះហើយបានជាគេច្រើនហៅថា «ភ្លេងមេមត់ » «រូបមេមត់» និង «លៀងមេមត់»។ មេមត់ គឺជាខ្មោចដូរចំបួរប្រចាំត្រកូល ហើយមាន "រូបស្នង" ដែលភាគច្រើនជាមនុស្សស្រី។ «រូបស្នង» ដើរតួនាទីសំខាន់ក្នុងកិច្ចជាន់មេមត់ រកមើលហេតុនៃវិបត្តិតូច ធំដែលកើតឡើងផ្ទាល់ខ្លួន, ក្នុងគ្រួសារ ឬតាមការពឹងពាក់ពីអ្នកស្រុកជិតឆ្ងាយឲ្យជួយព្យាបាល ដោយស្ដោះផ្លុំ ឬពេលបាត់បង់វត្ថុអីមួយ។ល។ លុះបានផល ឬជាពីជម្ងឺដោយធ្វើតាមពាក្យខ្មោចប្រាប់ យើងត្រូវលៀងកំសាន្តឲ្យអមនុស្សជាការដឹងគុណដែលប្រាប់ពីហេតុផល និងខំមើលយើងជា។ ពិធីលៀងនេះ គេហៅ «លៀងមេមត់»។

ក្នុងពិធីលៀងលៀងមេមត់នេះភ្លេងគឺជាគ្រឿងវណ្ដាប់មួយយ៉ាងសំខាន់ ដែលមិនអាចខ្វះបាន ត្បិតត្រូវលេងឲ្យមេមត់រាំលេងសប្បាយ។ កិច្ចពិធីលៀងមេមត់ មានរបៀបពីរយ៉ាង៖ ទី១ កិច្ចពិធីលៀងជាលក្ខណៈឯកជន ដោយមានរៀបចំសំណែនជាម្ហូបអាហារ ព្រមទាំងមានភ្លេងមេមត់ផង ដើម្បីជាការដឹងគុណដល់ខ្មោច ឬចំបួរ ដែលខំមើលជម្ងឺជា ឬរកវត្ថុអ្វីមួយដែលបានបាត់បង់ទៅហើយឃើញមកវិញ។ កិច្ចពិធីនេះ ច្រើនចាប់ធ្វើនៅពេលថ្ងៃត្រង់ ឬក៏រសៀល។ ចំណែកកិច្ចពិធីទី២ គឺលៀងមេមត់មានលក្ខណៈជាសហគមន៍ ដែលធ្វើរៀងរាល់ឆ្នាំ ឬអ្នកខ្លះ ភូមិខ្លះទាល់តែពីរ ឬបីឆ្នាំម្ដង ទោះជាឈឺ ឬមិនឈឺអីក៏ដោយ គឺត្រូវតែធ្វើពិធីលៀងមេមត់។ ក្នុងពិធីលៀងនេះដែររូបស្នងក៏បញ្ជាន់មេមត់ដែលជាគ្រូកំណើត ឬចំបួររបស់ខ្លួនឡើងរាំតាមចង្វាក់ភ្លេង ហើយអ្នកខ្លះគេឆ្លៀតមករកមើលពីវិបត្តិតូច ធំផ្ទាល់ខ្លួន ឬគ្រួសារ ហើយជួនកាលមេមត់ហ្នឹងក៏ព្យាបាលអ្នកជម្ងឺ ដោយស្ដោះព្រួសក្នុងពេលលៀងនោះទៀតផង។





លៀងមេមត់នៅភូមិនគរក្រៅ





លៀងមេមត់នៅភូមិថ្នល់ដាច់








*លៀងមេមត់នៅភូមិត្នោតជ្រុំ*

## ៥. ពិធីបុណ្យក្នុងសាសនា

*ពិធីបុណ្យក្នុងព្រះពុទ្ធសាសនាដែលបានធ្វើតាមទំនៀមប្រពៃណីនៅកម្ពុជាមានច្រើន ហើយពិធីបុណ្យទាំងនោះបានរៀបចំទៅតាមរដូវកាល ពោលគឺពិធីបុណ្យដប់ពីរខែនៃព្រះពុទ្ធសាសនា ឬហៅថា «បុណ្យទ្វាទសមាស»។ ប៉ុន្តែនៅទីនេះ យើងពុំលើកយកគ្រប់ពិធីបុណ្យក្នុងព្រះពុទ្ធសាសនាមកបង្ហាញទាំងអស់ទេ ដ្បិតពិធីទាំងនោះមានប្រារព្ធស្ទើរតែគ្រប់កន្លែងទាំងអស់នៅកម្ពុជា ពោលគឺលើកយកតែពិធីបុណ្យណាដែលមាន «កិច្ចពិសេស» ខុសពីពិធីបុណ្យផ្សេងៗមកបង្ហាញតែប៉ុណ្ណោះ។*

## ៥.១. ចូលបរិវាសកម្ម

- **ពេលវេលា៖ ធ្វើនៅខែបុស្ស-មាឃ (ខែមករា)**
- **ទីតាំង៖** *វត្តរុន, វត្តអធ្វារ, វត្តប្រាសាទធ្នង់រង្សីសិរីគង្គា (ភូមិម្កាក់) និងវត្តអធិបតី (ភូមិរើល)*
- **ពិពណ៌នា៖**

*ជារៀងរាល់មួយឆ្នាំម្តងនៅខែមាឃ ឬខែបុស្ស ព្រះសង្ឃនៅតាមវត្តនៅភូមិដូចបង្ហាញពីខាងលើតែងតែរៀបចំពិធីចូលបរិវាសកម្ម ទៅតាមប្រពៃណីតាមស្រុកភូមិ។ ពិធីនេះព្រះសង្ឃនៅវត្តក្នុងស្រុកដូចគ្នាបាននិមន្តមកចូលរួមនៅវត្តណាមួយដែលមានរៀបចំពិធីនេះ។ គោលបំណងសំខាន់នៃការរៀបចំធ្វើពិធីនេះ គឺជាការធ្វើទណ្ឌកម្មដាក់ទោសផ្ទាលភិក្ខុក្នុងព្រះពុទ្ធសាសនាដែលត្រូវអាបត្តិសង្ឃាទិសេស។ កិច្ចនេះដើមឡើយគេរៀបចំឡើងដោយស្ងាត់ៗ ជៀសវាងកុំឲ្យសង្ឃដែលទទួលទាន់ទណ្ឌកម្មនេះមានការខ្មាស់អៀន។ ប៉ុន្តែសព្វថ្ងៃពិធីនេះធ្វើឡើងជាចំហរពុំលាក់លៀមដូចមុនទៀតទេ។*









ចូលបរិវាសកម្មនៅវត្តរុន ភូមិតានី ឃុំរុនតាឯក

## ៥.២. មាឃបូជា

- **ពេលវេលា៖** ធ្វើនៅខែមាឃ (ខែកុម្ភៈ)
- **ទីតាំង៖** ភូមិនគរក្រៅ, ភូមិក្រវ៉ាន់, ភូមិប្រដាក, ភូមិទ្រៀក, ភូមិក្រសាំងលើង, ភូមិលលៃ, ភូមិដូនទំ, ភូមិចំបក់, ភូមិបាគង, និង ភូមិបង្កោង
- **ពិពណ៌នា៖**

មាឃបូជា ជាពិធីបុណ្យមួយសំខាន់បំផុតនៅក្នុងព្រះពុទ្ធសាសនា។ ពិធីបុណ្យមាឃបូជា គឺប្រារព្ធឡើងដើម្បីរំលឹកដល់ថ្ងៃដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសបង្កើត "ព្រះពុទ្ធសាសនា" នាថ្ងៃទី១៥កើត ខែមាឃ ឆ្នាំ៥៨៨ មុនស.គ.ក្រោយពីការត្រាស់ដឹងរបស់ព្រះអង្គ។ ពិធីនេះប្រារព្ធឡើងនៅតាមទីវត្តអារាម និងទីសក្ការបូជាសំខាន់។ ក្នុងពិធីនេះមានគ្រឿងសក្ការសំខាន់ៗដូចជា៖ បាយស្រី ទាន ធូប ផ្កា

ភ្ញី ផ្លែឈើ គេសជ្ជៗលៗ  នៅតាមវត្តមួយចំនួនព្រះសង្ឃតែងដឹកនាំពុទ្ធបរិស័ទបានដង្ហែព្រះពុទ្ធបដិមា ឬព្រះបរមសារីរិកធាតុ និងគ្រឿងសក្ការផ្សេងៗតាមផ្លូវនានាក្នុងភូមិស្រុក។ ដោយឡែកនៅតាមវត្តខ្លះនៅតំបន់អង្គរមានពូនភ្នំខ្សាច់ រៀបចំសម្អិតសម្អាងព្រះពុទ្ធបដិមា និងនិមន្តព្រះសង្ឃសូត្រមន្តរាប់បាត្រៗលៗ




បុណ្យមាឃបូជានៅវត្តដំណាក់

## ៥.៣. ទេសន៍មហាជាតក

- **ពេលវេលា៖** *ធ្វើនៅខែមាឃ (ខែកុម្ភៈ)*

- **ទីតាំង៖** *វត្តថ្មីដំរីសែនជ័យ, វត្តព្រះដាក់, វត្តដំណាក និងវត្តបន្ទាយក្បាលចិន, វត្តរុន, វត្តប្រាសាទបាគង, វត្តអដ្ធារ, វត្តកំពង់ភ្លុក, និងវត្តលលៃ*
- **ពិពណ៌នា៖**

*ពុទ្ធសាសនិកមួយចំនួននៅតំបន់អង្គរ តែងធ្វើពិធីបុណ្យមួយហៅថា «ទេសន៍មហាជាតិ» ដែលទាក់ទងនឹងរឿងរ៉ាវ «ជាតិ» ទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធ មុនជាតិដែលព្រះអង្គបានត្រាស់ដឹង ពោលគឺពេលដែលព្រះអង្គនៅជាព្រះពោធិសត្វ ហើយចាប់កំណើតផ្សេងៗគ្នាជាមនុស្ស ឬជាសត្វជាដើម  ជាពិសេសសំដៅដល់ពិធីបុណ្យដែលមានការទេសនាឲ្យពុទ្ធបរិស័ទបានស្ដាប់ពីរឿងព្រះវេស្សន្តរ ដែលជាជាតិចុងក្រោយបង្អស់ ដ្បិតព្រះពោធិសត្វនៅក្នុងជាតិនោះមានព្រះនាមថា «ព្រះវេស្សន្តរ»។  ខ្មែរមានការនិយមព្រះវេស្សន្តរជាតកតាំងពីសម័យបុរាណមកម្ល៉េះ  ព្រោះយើងឃើញជាចម្លាក់តាមប្រាសាទក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧មួយចំនួនដែលបង្ហាញឈុតខ្លះនៃរឿងនេះ និងមានជាគំនូរនៅតាមវត្ត។ល។*

*ក្នុងពីធីបុណ្យនេះ មានទំនៀមសម្ដែងជាឈុតដែលទាក់ទងនឹងរឿងទេសន៍នេះតែម្ដង ឯអ្នកសម្ដែង គឺជាអ្នកស្រុកធម្មតា។  នៅខេត្តសៀមរាប គេនិយមប្រារព្ធពិធីនេះរយៈពេលបីថ្ងៃ។ សង្ខេបឲ្យខ្លីមក គឺចាប់ផ្ដើមពីប្រុងពលី, បន្ទាប់មកគឺកិច្ចបួងសួង រួចហើយទេសន៍ពីកណ្ឌទី១ដល់កណ្ឌទី១៣ ដែលចប់នៅយប់ថ្ងៃទីពីរ។ នៅថ្ងៃទី៣ និមន្តព្រះសង្ឃទេសន៍  «អានិសង្ស និងទេសន៍មហាជាតក» រួចហើយក៏ធ្វើបញ្ចប់កម្មវិធី។*











*បុណ្យទេសន៍មហាជាតកនៅវត្តបន្ទាយក្បាលចិន*

## ៥.៤. វិសាខបូជា

- **ពេលវេលា៖** *ធ្វើនៅខែវិសាខ (ខែឧសភា)*
- **ទីតាំង៖** *វត្តអង្គរអង្គរខាងត្បូង, វត្តថ្មីដំរីសែនជ័យ, វត្តដំណាក និងវត្តលលៃ*
- **ពិពណ៌នា៖**

*ពិធីបុណ្យវិសាខបូជា  គឺជាពិធីបុណ្យដ៏ធំមួយនៅក្នុងព្រះពុទ្ធសាសនា ដែលតែងតែធ្វើនៅថ្ងៃ១៥កើតពេញបូរណ៌មី  ខែវិសាខជារៀងរាល់ឆ្នាំ ដើម្បីរំឭកដល់ថ្ងៃប្រសូត្រ (ថ្ងៃសុក្រ ពេញបូណ៌មី ខែវិសាខ ឆ្នាំច មុនស.គ.៦២៣ឆ្នាំ), ការត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ*

(ថ្ងៃពុធ ពេញបូណ៌មី ខែវិសាខ ឆ្នាំរកា នាវេលាទៀបភ្លឺ ក្រោយពីបួសអស់រយៈពេល៦ឆ្នាំ)  និងថ្ងៃរំលត់ខន្ធចូលបរិនិព្វាន្ទ (ថ្ងៃអង្គារ ពេញបូណ៌មី ខែវិសាខ ឆ្នាំម្សាញ់ ក្នុងព្រះជន្ម៨០ព្រះវស្សា)។ នៅតំបន់អង្គរ ក្នុងថ្ងៃបុណ្យវិសាខបូជានេះ អ្នកស្រុកមានទំនៀមពិសេសមួយ ពោលគឺអ្នកស្រុកតែងឲ្យកូនប្រុសបួសជាសង្ឃ ឯកូនស្រីបួសជាដូនជី។  ក្នុងពិធីបួសនេះ នាគមកពីវត្តមួយចំនួនដែលនៅជុំវិញអង្គរ មកជួបជុំគ្នានៅប្រាសាទអង្គរវត្ត ដើម្បីដង្ហែនៅនាគ។














*បុណ្យពិសាខបូជានៅវត្តអង្គរខាងត្បូង*

## ៥.៥. ចូលវស្សា

- **ពេលវេលា៖** *ធ្វើនៅខែអាសាឍ (ខែកក្កដា)*
- **ទីតាំង៖** *មានប្រារព្ធពិធីបុណ្យគ្រប់វត្ត*
- **ពិពណ៌នា៖**

*ជាទូទៅថ្ងៃចូលវស្សា គឺកំណត់ចូលនៅថ្ងៃ១រោច ខែអាសាឍ និងចេញនៅថ្ងៃ១៥កើត ខែអស្សុជ។ ឆ្នាំខ្លះ គឺចូលវស្សានៅថ្ងៃ១រោច ខែទុតិយាសាឍ និងចេញនៅថ្ងៃ១៥កើត ខែអស្សុជ (ករណីខែអាសាឍត្រួត)។ ក្នុងពិធីនេះភិក្ខុសង្ឃត្រូវគង់នៅក្នុងវត្ត ឬទីកន្លែងណាមួយក្រៅវត្តក្តី ដោយមិនត្រូវនិមន្តទៅណាអស់កំណត់៣ខែ)។ ប៉ុន្តែព្រះបញ្ញត្តិនេះត្រូវលើកលែងក្នុងករណីចាំបាច់មួយចំនួន តែភិក្ខុសង្ឃ*

ត្រូវត្រឡប់មកវិញក្នុងរវាង៧ថ្ងៃ។ ក្នុងពិធីចូលវស្សានេះ មានកិច្ចពិធីសិតទៀនវស្សាថ្វាយជាសក្ការៈដល់ព្រះរតនត្រ័យ, កិច្ចពិធីហែទៀនវស្សាទៅតម្កល់នៅទីតាំងដែលបានកំណត់។ គោលបំណងនៃការចូលវស្សា ព្រោះបរិស័ទមិនពេញចិត្តដែលភិក្ខុសង្ឃនិមន្តទៅមកគ្រប់កាលរដូវដូចសាមញ្ញជន ដែលបណ្ដាលឲ្យជាន់ស្មៅទាំងឡាយ និងបៀតបៀនវត្ថុដែលមានជីវិត ហើយម្យ៉ាងទៀតជារដូវភ្លៀងធ្លាក់ដែលការចេញដំណើរទៅឆ្ងាយអាចនឹងប្រទះគ្រោះអាសន្នជាយថាហេតុ ដូច្នេះហើយព្រះសម្មាសម្ពុទ្ធក៏បញ្ញត្តិឲ្យសង្ឃទាំងអស់គង់ចាំព្រះវស្សាចំនួន៣ខែ។

ដោយឡែកនៅតាមវត្តមួយចំនួននៅតំបន់អង្គរ មានទំនៀមពិសេសមួយ គឺបន្ទាប់ពីព្រះសង្ឃចូលវស្សាបានកន្លះខែ គឺនៅថ្ងៃ១៥រោច ខែអាសាឍ ឬទុតិយាសាឍ (ករណីអាសាឍទ្វេត) អ្នកភូមិប្រដាក, ភូមិអូរទទឹង, ភូមិតាត្រៃ ភូមិថ្នល់បណ្ដោយ, ភូមិគីរីមានន្ទ, ភូមិតាបាង និងភូមិតាកុស ដែលជាចំណុះដើងវត្តប្រដាក និងវត្តស្រះជុំ បានរៀបចំពិធីមួយហៅ «សីលដំបូង» ឬ «សីលមួយ» ដែលអ្នកស្រុកយល់ថាជា ថ្ងៃសីលដ៏វិសេសជាងថ្ងៃសីលធម្មតា។ ពិធីបុណ្យនេះមានរយៈពេល២ថ្ងៃគឺ៖ នៅថ្ងៃទី១ មុនធ្វើពិធីបុណ្យមួយថ្ងៃ អ្នកភូមិនាំគ្នាវេចនំអន្សម នំគម និងនំជាល ដើម្បីយកទៅប្រគេនព្រះសង្ឃ។ ចំណែកពុទ្ធបរិស័ទដែលរក្សាសីលប្រាំបី ឬសីលដប់ ទៅវត្តដើម្បីសមាទានសីល និងចម្រើនព្រះបរិត្ត។ នៅថ្ងៃទី២អ្នកភូមិទាំងចាស់ទាំងក្មេងបានមកជួបជុំគ្នានៅវត្ត ដោយមានម្ហូបអាហារ នំចំណី និងទេយ្យទានដើម្បីប្រគេនព្រះសង្ឃ និងដល់តាយាយដែលកាន់សីលប្រាំបី ឬសីលដប់។










បុណ្យចូលវស្សានៅវត្តប្រដាក

## ៥.៦. ចេញវស្សា

- **ពេលវេលា៖** ធ្វើនៅខែអស្សុជ (ខែតុលា)
- **ទីតាំង៖** មានប្រារព្ធពិធីបុណ្យគ្រប់វត្ត
- **ពិពណ៌នា៖**

«ចេញវស្សា» ជាពាក្យដែលពុទ្ធបរិស័ទហៅសម្គាល់ថ្ងៃពេញបូណ៌មី ខែអស្សុជ ប៉ុន្តែតាមពុទ្ធសាសនាហៅថា «បវារណា»។ បវារណា មានន័យថា ការបើកឲ្យនិយាយ សួរតាមការគួរ។ កិច្ចបវារណានេះ តាមពុទ្ធានុញ្ញាតិ គឺត្រូវនៅថ្ងៃពេញ បូណ៌មី ខែអស្សុជ

ដោយគិតចាប់តាំងពីថ្ងៃ១រោច ខែអាសាឍ ដែលជាថ្ងៃចូលវស្សាមករហូតគម្រប់រយៈពេញ៣ខែ ហើយក្នុងមួយឆ្នាំអាចធ្វើបានតែម្តងប៉ុណ្ណោះ។ ចេញវស្សា ឬបវារណា ជាកិច្ចរបស់ព្រះសង្ឃសុទ្ធសាធ ពុំទាក់ទងនឹងពុទ្ធសាសនិកទេ ប៉ុន្តែ ដោយសារមានសទ្ធា និងដើម្បីប្រាថ្នាកុសលផលបុណ្យ ពុទ្ធសាសនិកបានរៀបចំគ្រឿង បូជាមួយចំនួនប្រគេនព្រះសង្ឃនៅពេលព្រឹក ហើយព្រះសង្ឃមានធ្វើកិច្ចផ្សេងៗមួយចំនួនដូចជា ទេសនាគម្ពីរនានា ជាពិសេសទេសនាមហាជាតក។

ក្នុងពេលចេញវស្សា វត្តមួយចំនួននៅសៀមរាបអង្គរ ព្រះសង្ឃ និងអ្នកស្រុកមានទំនៀមមួយ គឺរៀបចំសំពៅ ឬសង្ឃឹក ដែលនៅក្នុងនោះមានដាក់ស្លាធម៌ដូង បាយស្រី បាយសម្ងរ បង្អែមចម្អាប មាន់ស្ងោរ ផ្លែឈើ ទឹកសុទ្ធ ទឹកក្រូច ស្រា ខ្មើយ លូ សណ្តែក គ្រឿងស្លអង្ករ ចង្ក្រាន ចាន ឆ្នាំង ឱស និងគ្រឿងតែងខ្លួន។ល។ ទៅបណ្តែតតាមស្ទឹង និងទន្លេនៅវេលាយប់ លើកលែងតែនៅកំពង់ភ្លុកគេធ្វើនៅពេលថ្ងៃត្រង់នៃថ្ងៃ១៥កើត ខែអស្សុជ ចំថ្ងៃចេញវស្សាតែម្តង។









បុណ្យចេញវស្សានៅវត្តអារញ្ញសាគរ







បុណ្យចេញវស្សានៅកំពង់ភ្លុក

# ឯកសារពិគ្រោះ


*ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ* (២០១៧). *បញ្ជីសារពើភណ្ឌមរតកវប្បធម៌អរូបីកម្ពុជា*, Inventory of Intangible Cultural Heritage of Cambodia, *ភ្នំពេញ*

*ឆាន់ សុភីនី, សោ ចន្ធា, តូច សុភៈ, ជា សំបូរ, អាន សីមា, អ៊ូ គង្គា* (២០២១). *កិច្ចពិធីនៅចុងវដ្តស្រូវ៖ ករណីឡើងមាយនៅភូមិបង្កោង*, ទស្សនាវដ្តីព្រះនគរ, *លេខ៣, ទំព័រ. ១៧៣-១៨៦, ភ្នំពេញ*

*ព្រាប ចាន់ម៉ារ៉ា* (២០២០). *ជំនឿផ្សេងៗ និងពុទ្ធសាសនានៅកម្ពុជា*, ព្រឹត្តបត្រសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, *លេខ៣, ទំព័រ. ៣១-៤៥, ភ្នំពេញ*

(២០២២) .*តំបន់អង្គរ៖ បេតិកភណ្ឌវប្បធម៌ដ៏រស់រវើក*, ព្រឹត្តបត្រសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, *លេខ៥, ទំព័រ. ១-២៥, ភ្នំពេញ*

*សាម ច័ន្ទវីរៈ* (២០០៩-២០១០). *ពិធីសុំទឹកភ្លៀង*, កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, *លេខ៥, ទំព័រ.២០-២៣, ភ្នំពេញ*

*ស៊ុន ចាន់ដឹប* (២០០៦-២០០៧). *ស្រូវកញ្ចើ*, កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, *លេខ២, ទំព័រ.៥០-៥៤, ភ្នំពេញ*

អាំង ជូលាន, អេរិក ប្រេណូវិត្ស, អាស៊ី ថមសុន  (១៩៩៧). អង្គរ៖ អតីត-បច្ចុប្បន្ន-អនាគត, អាជ្ញាធរអប្សរា, ភ្នំពេញ

អាំង ជូលាន (២០១០-២០១១). ឆ្វងចេត្រ, កម្រែងអត្ថបទក្នុងបណ្ដាញពត៌មានវប្បធម៌ខ្មែរ, លេខ៦, ទំព័រ. ៣២-៣៥, ភ្នំពេញ

អាំង ជូលាន ព្រាបចាន់ម៉ារ៉ា (២០០៧). ដំណើរជីវិតមនុស្សខ្មែរ មើលតាមពិធីឆ្លងវ័យ, បោះពុម្ពលើកទី១, រ៉ែយំ, ភ្នំពេញ

មជ្ឈមណ្ឌលស្រាវជ្រាវ វិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (២០១៧). ពិធីលៀងមេមត់៖ ស្រុកអង្គរជ័យ ខេត្តកំពត, ភ្នំពេញ